# បញ្ហានានាដែលមាននៅក្នុង
# រឿងក្តរដ្ឋប្បវេណី



ក្រសួងយុត្តិធម៌ វិទ្យាស្ថានស្រាវជ្រាវទូទៅអំពីកិច្ចការច្បាប់
នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ
Prof. Higashio Kazuyuki, Prof. Yukawa Ryo, Prof. Uchiyama Jun

# 2 ការជំនុំជម្រះសាជាថ្មី

# ករណីសិក្សា (រួម)





X

នៅថ្ងៃទី1 ខែមករា ឆ្នាំ2016  ខ្ញុំបានឱ្យ Yខ្ចីប្រាក់ 1ម៉ឺនដុល្លារអាមេរិក។ កាលកំណត់សងគឺថ្ងៃទី1 ខែកក្កដា។

ទេ! ខ្ញុំមិនបានខ្ចីទេ។



Y

# ករណីសិក្សា (រួម)




ការទាមទារ : ការទាមទារឱ្យសងប្រាក់កម្ចីដោយផ្អែកលើកិច្ចសន្យាខ្ចីបរិភោគ

# ករណីសិក្សា (រូម)




សាលក្រមទទួលស្គាល់នូវការទាមទារ → ចូលជាស្ថាពរ

# ករណីសិក្សា (រូម)

សាលក្រមចាញ់ក្ដីបានចូលជាស្ថាពរ តែ Y មិនស្របចិត្ត។
គាត់គិតចង់ធ្វើយ៉ាងដូចម្ដេចប្ដូរខ្លឹមសារនៃសាលក្រមដែលបានចូលជាស្ថាពរហើយនោះ។
តើអាចធ្វើបែបនេះបានឬទេ ?




សាលក្រមទទួលស្គាល់នូវការទាមទារ → ចូលជាស្ថាពរ

# ការជំនុំជម្រះសាជាថ្មី គឺជា

ស្ដីពីវិធីវិវាទអំពីអានុភាពនៃសាលក្រមដែលបានចូលជាស្ថាពរហើយ គឺមានរបបនៃការជំនុំជម្រះសាជាថ្មី(ពីមាត្រា307 ទៅ)។

ថ្ងៃនេះ ខ្ញុំសូមពន្យល់អំពីការជំនុំជម្រះសាជាថ្មី។

ក៏ប៉ុន្តែ ការជំនុំជម្រះសាជាថ្មីនេះ គឺជារបបមួយពិសេសណាស់។ តាមរយៈសិក្ខាសាលានេះ សូមលោកអ្នកចងចាំថា គេទទួលស្គាល់ការជំនុំជម្រះសាជាថ្មីក្រោមល័ក្ខខ័ណ្ឌតឹងរ៉ឹងណាស់។

# ការចូលជាស្ថាពរនៃសាលក្រម

មុននឹងពិចារណាអំពីការជំនុំជម្រះសាជាថ្មី សូមមើលឡើងវិញអំពីការចូលជាស្ថាពរនៃសាលក្រមសិន។

សាលក្រមចូលជាស្ថាពរតាមរយៈការកន្លងផុតទៅនៃអំឡុងពេលប្ដឹងឧបាស្រ័យ ឬ តាមរយៈការចេញសាលដីការបស់តុលាការជាន់ខ្ពស់(មាត្រា193)។

តាមរយៈការចូលជាស្ថាពរនៃសាលក្រម អានុភាពនៃអាជ្ញាអស់ជំនុំត្រូវកើតឡើង(មាត្រា194)

នៅក្នុង【ករណីសិក្សា】 អត្ថិភាពនៃសិទ្ធិទាមទារឱ្យសង1ម៉ឺនដុល្លារអាមេរិកបានចូលជាស្ថាពរ។ សាលក្រមបានចូលជាស្ថាពរ ដូច្នេះ Y មិនអាចវិវាទលើសពីនេះបានទេ។

# ការជំនុំជម្រះសាជាថ្មី គឺជា

បណ្តឹង គឺសម្រាប់ដោះស្រាយវិវាទ។ ស្តីពីទំនាក់ទំនងសិទ្ធិដែលត្រូវបានកំណត់ជាស្ថាពរម្តងរួចហើយ ប្រសិនជាឱ្យអាចតតាំងគ្នាម្តងទៀតទៅ វិវាទនោះមិនដឹងជាពេលណាទើបអាចដោះស្រាយបានទេ។

ផ្ទុយទៅវិញ បើសិនជារក្សាទុកនូវអានុភាពនៃសាលក្រមដែលបានចូលជាស្ថាពរដដែលនៃសាលក្រមដែលមានវិការៈធ្ងន់ធ្ងរក្នុងការវិនិច្ឆ័យ ក៏មិនត្រឹមត្រូវឡើយ។

មានតែករណីយ៉ាងពិសេសទេ ដែលគេទទួលស្គាល់នូវបណ្តឹងជំនុំជម្រះសាជាថ្មី។

# សេចក្ដីពន្យល់ត្រួសៗអំពីនីតិវិធីនៃការជំនុំជម្រះសាជាថ្មី

បណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី: ដាក់ពាក្យបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី

ដំណាក់កាលទី១ : ការជំនុំជម្រះអំពីភាពស្របច្បាប់នៃបណ្ដឹង និង អត្ថិភាព ឬ នត្ថិភាពនៃមូលហេតុនៃការជំនុំជម្រះសាជាថ្មី

ដីកាសម្រេចចាប់ផ្ដើមជំនុំជម្រះសាជាថ្មី (មាត្រា315 កថាខណ្ឌទី1)

ដីកាសម្រេចលើកចោលនូវបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី(មាត្រា314 កថាខណ្ឌទី1)
ដីកាសម្រេចច្រានចោលការទាមទារឱ្យជំនុំជម្រះសាជាថ្មី(មាត្រា314 កថាខណ្ឌទី2)

ដំណាក់កាលទី២ : ការវិនិច្ឆ័យលើអង្គសេចក្ដី

សាលក្រម

សាលក្រមច្រានចោលនូវការទាមទារឱ្យជំនុំជម្រះសាជាថ្មី (មាត្រា316 កថាខណ្ឌទី2)

លុបចោលនូវសាលក្រម សាលដីកាដើម ហើយសម្រេចសេចក្ដីថ្មី (មាត្រា316 កថាខណ្ឌទី3)

# សេចក្តីពន្យល់ត្រួសៗអំពីនីតិវិធីនៃការជំនុំជម្រះសាជាថ្មី

<u>បណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី: ដាក់ពាក្យបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី</u>

ដំណាក់កាលទី១ : ការជំនុំជម្រះអំពីភាពស្របច្បាប់នៃបណ្តឹង និង អត្ថិភាព ឬ នត្ថិភាពនៃមូលហេតុនៃការជំនុំជម្រះសាជាថ្មី

ដីកាសម្រេចចាប់ផ្តើមជំនុំជម្រះសាជាថ្មី (មាត្រា315 កថាខណ្ឌទី1)

ដីកាសម្រេចលើកចោលនូវបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី(មាត្រា314 កថាខណ្ឌទី1)
ដីកាសម្រេចច្រានចោលការទាមទារឱ្យជំនុំជម្រះសាជាថ្មី(មាត្រា314 កថាខណ្ឌទី2)

ដំណាក់កាលទី២ : ការវិនិច្ឆ័យលើអង្គសេចក្តី

សាលក្រម សាលក្រមច្រានចោលនូវការទាមទារឱ្យជំនុំជម្រះសាជាថ្មី (មាត្រា316 កថាខណ្ឌទី2)
លុបចោលនូវសាលក្រម សាលដីកាដើម ហើយសម្រេចសេចក្តីថ្មី (មាត្រា316 កថាខណ្ឌទី3)

# បណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី

1 ពាក្យបណ្ដឹងទាមទារឲ្យជំនុំជម្រះសាជាថ្មី

2 សមត្ថកិច្ចនៃការជំនុំជម្រះសាជាថ្មី

3 អំឡុងនៃការជំនុំជម្រះសាជាថ្មី

# ពាក្យបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី

ការជំនុំជម្រះសាជាថ្មី គឺជានីតិវិធីទាមទារឱ្យលុបចោលនូវសាលក្រម ឬ សាលដីកាចុងក្រោយដែលបានចូលជាស្ថាពរហើយ(មាត្រា 307 កថាខណ្ឌទី1 វាក្យខណ្ឌទី1)។

បន្ទាប់មក តើត្រូវសរសេរយ៉ាងដូចម្ដេចនៅក្នុងពាក្យបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី?

ជាពិសេស ត្រង់ចំណុចដែលត្រូវនឹង “ខ្លឹមសារនៃសាលក្រមដែលទាមទារ” នៃពាក្យបណ្ដឹងធម្មតា តើក្នុងពាក្យបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី គេត្រូវសរសេរអ្វីខ្លះ ?

# ករណីសិក្សា (រូម)

Y បានដាក់ពាក្យបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី ដើម្បីទាមទារឱ្យលុបចោលនូវសាលក្រមដែលបានចូលជាស្ថាពរនេះ។




សាលក្រមទទួលស្គាល់នូវការទាមទារ → ចូលជាស្ថាពរ

# ពាក្យបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី

ចំណុចដែលត្រូវសរសេរ(មាត្រា312 កថាខណ្ឌទី1)

ក-ឈ្មោះ ឬ នាមករណ៍ និង អាសយដ្ឋានរបស់ភាគី

ឈ្មោះ និង អាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់

ខ-①សញ្ញាណនៃសាលក្រម ឬ សាលដីកាដែលជាកម្មវត្ថុនៃបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី

→ អាចបញ្ជាក់បានតាមរយៈភាគី និងលេខនៃរឿងក្ដី ជាអាទ៍

② សេចក្ដីទាមទារឱ្យជំនុំជម្រះសាជាថ្មីចំពោះសាលក្រម ឬ សាលដីកានោះ

គ- អង្គហេតុដែលត្រូវនឹងមូលហេតុនៃការជំនុំជម្រះសាជាថ្មី

ឯកសារដែលត្រូវភ្ជាប់(មាត្រា312 កថាខណ្ឌទី2)

ឯកសារចម្លងនៃសាលក្រម ឬ សាលដីកាដែលជាកម្មវត្ថុនៃបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី

# ពាក្យបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី ១

## ពាក្យបណ្ដឹង

【ភាគី】

ដើមចោទនៃបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី

○○○(អាសយដ្ឋាន)

Y(ឈ្មោះ)

ចុងចម្លើយនៃបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី

□□□(អាសយដ្ឋាន)

X(ឈ្មោះ)

# ពាក្យបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី ១(ត)

## ពាក្យបណ្ដឹង

【សញ្ញាណនៃសាលក្រមដែលជាកម្មវត្ថុ】

- ស្ដីពីរឿងក្ដី (លេខនៃរឿងក្ដី) នៃសាលាដំបូងរាជធានីភ្នំពេញ រវាងដើមចោទនៃបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី និង ចុងចម្លើយនៃបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី គឺជាសាលក្រមដែលសាលាដំបូងរាជធានីភ្នំពេញនេះបានប្រកាសនៅថ្ងៃទី1 ខែមេសា ឆ្នាំ2017 (ចូលជាស្ថាពរនៅថ្ងៃទី ... ខែ ... ឆ្នាំ 2017)

- សេចក្ដីសម្រេចបញ្ចប់

  "បង្គាប់ឱ្យចុងចម្លើយបង់ប្រាក់១ម៉ឺនដុល្លារអាមេរិកទៅឱ្យដើមចោទ។
  ប្រាក់ប្រដាប់ក្ដី គឺជាបន្ទុករបស់ចុងចម្លើយ។
  សាលក្រមនេះអាចអនុវត្តជាបណ្ដោះអាសន្នបាន"

# ពាក្យបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី ១(ត)

**ពាក្យបណ្ដឹង**

【សេចក្ដីទាមទារឲ្យជំនុំជម្រះសាជាថ្មី】

“លុបចោលនូវសាលក្រមដើម។
ច្រានចោលនូវការទាមទាររបស់ចុងចម្លើយនៃបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី។”

【មូលហេតុនៃការជំនុំជម្រះសាជាថ្មី】

សាលក្រមដែលបានចូលជាស្ថាពរ គឺជាសាលក្រមដែលត្រូវបានសម្រេចដោយផ្អែកលើកិច្ចសន្យាក្លែងក្លាយ។ ស្ដីពីការធ្វើកិច្ចសន្យាក្លែងក្លាយនេះ សាលក្រមសម្រេចផ្ដន្ទាទោសបានចូលជាស្ថាពរ។

# ឧទាហរណ៍

ផ្ទុយទៅវិញ បើសិនជាសាលក្រមច្រានចោលនូវការទាមទារបានចូលជាស្ថាពរ ហើយ X បានដាក់ពាក្យបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីវិញ តើក្នុងករណីនេះ ត្រូវសរសេរអំពី "ខ្លឹមសារនៃសាលក្រមដែលទាមទារ" នេះយ៉ាងដូចម្តេចដែរ?




សាលក្រមច្រានចោលនូវការទាមទារ → ចូលជាស្ថាពរ

# ពាក្យបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី ២

## ពាក្យបណ្ដឹង

【ភាគី】

ដើមចោទនៃបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី

○○○(អាសយដ្ឋាន)

X(ឈ្មោះ)

ចុងចម្លើយនៃបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី

□□□(អាសយដ្ឋាន)

Y(ឈ្មោះ)

# ពាក្យបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី ២(ត)

## ពាក្យបណ្ដឹង

【សញ្ញាណនៃសាលក្រមដែលជាកម្មវត្ថុ】

- ស្ដីពីរឿងក្ដី (លេខនៃរឿងក្ដី)នៃសាលាដំបូងរាជធានីភ្នំពេញ រវាងដើមចោទនៃបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី និង ចុងចម្លើយនៃបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី គឺជាសាលក្រមដែលសាលាដំបូងរាជធានីភ្នំពេញនេះបានប្រកាសនៅថ្ងៃទី1 ខែមេសា ឆ្នាំ2015 (ចូលជាស្ថាពរនៅថ្ងៃទី ... ខែ ... ឆ្នាំ 2015)

- សេចក្ដីសម្រេចបញ្ចប់
  "ច្រានចោលនូវការទាមទាររបស់ដើមចោទ។
  ប្រាក់ប្រដាប់ក្ដី គឺជាបន្ទុករបស់ដើមចោទ។"

# ពាក្យបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី ២(ត)

## ពាក្យបណ្ដឹង

【សេចក្ដីទាមទារឲ្យជំនុំជម្រះសាជាថ្មី】

“លុបចោលនូវសាលក្រមដើម។
បង្គាប់ឱ្យចុងចម្លើយនៃបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី បង់ប្រាក់១ម៉ឺនដុល្លារអាមេរិកទៅឲ្យដើមចោទនៃបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី។”

【មូលហេតុនៃការជំនុំជម្រះសាជាថ្មី】

សាលក្រមដែលបានចូលជាស្ថាពរ គឺជាសាលក្រមដែលត្រូវបានសម្រេចដោយផ្អែកលើចម្លើយជាកសិណសាក្សីរបស់សាក្សីដែលត្រូវគេគម្រាមកំហែង។
ស្ដីពីសាក្សីដែលបានគម្រាមកំហែងនេះ សាលក្រមសម្រេចផ្ដន្ទាទោសសាក្សីនេះបានចូលជាស្ថាពរ។

# ពាក្យបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី

ក្នុងករណីដែលពាក្យបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីមិនគ្រប់លក្ខណៈ តើតុលាការត្រូវចាត់ចែងយ៉ាងដូចម្ដេចដែរ?

តុលាការត្រូវចាត់ចែងឱ្យកែតម្រូវ ដូចបណ្ដឹងធម្មតាដែរ (មាត្រា310, មាត្រា78 កថាខណ្ឌទី1)។
ក្នុងករណីដែលមិនកែតម្រូវទេ ត្រូវលើកពាក្យបណ្ដឹងនោះចោល(មាត្រា310, មាត្រា78 កថាខណ្ឌទី2)។

# សមត្ថកិច្ចនៃការជំនុំជម្រះសាជាថ្មី

តើត្រូវដាក់ពាក្យបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីទៅតុលាការណាមួយ?

ក្នុងករណីដែលសាលក្រមចូលជាស្ថាពរនៅសាលាដំបូង (ករណីដែលគ្មានបណ្ដឹងឧបាស្រ័យ) សាលាដំបូងនោះមានសមត្ថកិច្ចលើបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី(មាត្រា309 កថាខណ្ឌទី1)។

ក្នុងករណីដែលសាលក្រមរបស់សាលាដំបូងត្រូវបានប្ដឹងទៅសាលាឧទ្ធរណ៍ ហើយតុលាការនៃបណ្ដឹងឧទ្ធរណ៍បានវិនិច្ឆ័យទៅលើអង្គសេចក្ដី សាលដីកានៃការជំនុំជម្រះបណ្ដឹងឧទ្ធរណ៍នោះគឺជាកម្មវត្ថុនៃការជំនុំជម្រះសាជាថ្មី(មាត្រា307 កថាខណ្ឌទី3)។ ដូច្នេះ ត្រូវដាក់ពាក្យបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីទៅតុលាការនៃបណ្ដឹងឧទ្ធរណ៍នោះដែរ។

# អំឡុងពេលនៃការជំនុំជម្រះសាជាថ្មី

តើបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី ត្រូវដាក់ដល់ពេលណាដែរ?

ប្រសិនជាអនុញ្ញាតឱ្យដាក់រហូតដល់ពេលណាក៏បានដែរនោះ ស្ថេរភាពគតិយុត្តនឹងបាត់បង់។

អំឡុងពេលនៃការដាក់ពាក្យបណ្ដឹងទាមទារឱ្យជំនុំម្រះសាជាថ្មី ត្រូវបានកម្រិត។
បណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីដែលដាក់ក្រោយអំឡុងពេលនេះកន្លងផុតទៅ គឺខុសច្បាប់។

# អំឡុងពេលនៃការជំនុំជម្រះសាជាថ្មី

ការកម្រិតនៃអំឡុងពេល ១

ក្នុងអំឡុងពេល៣០ថ្ងៃបន្ទាប់ពីថ្ងៃដែលបានដឹងអំពីមូលហេតុនៃការជំនុំជម្រះសាជាថ្មី ក្រោយពេលដែលសាលក្រម ឬ សាលដីកាបានចូលជាស្ថាពរហើយ (មាត្រា311 កថាខណ្ឌទី1 វាក្យខណ្ឌទី1)

→ អំឡុងពេលនេះមិនអាចពន្យារបានឡើយ(មាត្រា311 កថាខណ្ឌទី២។ សូមមើល មាត្រា244 កថាខណ្ឌទី1 វាក្យខណ្ឌទី2)។

ការកម្រិតនៃអំឡុងពេល ២

ក្នុងកំឡុងពេល៥ឆ្នាំ ដោយគិតពីថ្ងៃដែលសាលក្រម ឬ សាលដីកាបានចូលជាស្ថាពរ ឬ ថ្ងៃដែលមូលហេតុនៃការជំនុំជម្រះសាជាថ្មីកើតមានឡើង(ករណីដែលកើតមានឡើងក្រោយពេលសាលក្រម ឬ សាលដីកាបានចូលជាស្ថាពរ) (មាត្រា311 កថាខណ្ឌទី3 វាក្យខណ្ឌទី1)

→ គ្មានពាក់ព័ន្ធនឹងបញ្ហាថា តើភាគីបានដឹង ឬមិនដឹងទេ។

※ ចំពោះមូលហេតុនៃបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីមួយភាគ គេមិនអនុវត្តអំពីការកម្រិតនៃអំឡុងពេល ១ និង អំពីការការកម្រិតនៃអំឡុងពេលពេល ២ទេ។ (មាត្រា311 កថាខណ្ឌទី1 វាក្យខណ្ឌទី2, កថាខណ្ឌទី3 វាក្យខណ្ឌទី2)

# ការកម្រិតនៃអំឡុងពេល ១

ចាញ់ក្ដីហើយ តែបានស្រាវជ្រាវទៅឃើញថា X និងចៅក្រមទទួលបន្ទុក ត្រូវជាបងប្អូនជីដូនមួយនឹងគ្នា។
ត្រូវតែដាក់ពាក្យបណ្ដឹងទាមទារឱ្យធ្វើការជំនុំជម្រះសាជាថ្មីហើយ! (មាត្រា307 កថាខណ្ឌទី1 ចំណុច ខ, មាត្រា27 កថាខណ្ឌទី1 ចំណុច ខ.)




សាលក្រមទទួលស្គាល់នូវការទាមទារ → ចូលជាស្ថាពរ

# ការកម្រិតនៃអំឡុងពេល ១

ចាំបាច់ដាក់ពាក្យបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី ក្នុងកំឡុងពេល៣០ថ្ងៃ ដោយគិតពីថ្ងៃដែលបានដឹងថាគេត្រូវជាបងប្អូនជីដូនមួយនឹងគ្នា។




សាលក្រមទទួលស្គាល់នូវការទាមទារ → ចូលជាស្ថាពរ

# ការកម្រិតនៃអំឡុងពេល ២

ចាញ់ក្តីហើយ តែបានស្រាវជ្រាវទៅឃើញថា X
និងចៅក្រមទទួលបន្ទុក ត្រូវជាបងប្អូនជីដូនមួយ
នឹងគ្នា។
ក៏ប៉ុន្តែពេលវេលាបានកន្លងផុត៦ឆ្នាំហើយ ពីថ្ងៃ
ដែលសាលក្រមនោះបានចូលជាស្ថាពរ ....។




សាលក្រមទទួលស្គាល់នូវការទាមទារ → ចូលជាស្ថាពរ

# ការកម្រិតនៃអំឡុងពេល ២

៥ឆ្នាំកន្លងផុតហើយ ដោយគិតពីថ្ងៃដែលសាលក្រមនោះចូលជាស្ថាពរ ដូច្នេះមិនអាចដាក់ពាក្យបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីបានទេ។




សាលក្រមទទួលស្គាល់នូវការទាមទារ → ចូលជាស្ថាពរ

# សេចក្តីពន្យល់ត្រួសៗអំពីនីតិវិធីនៃការជំនុំជម្រះសាជាថ្មី

បណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី : ដាក់ពាក្យបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី

<u>ដំណាក់កាលទី១ : ការជំនុំជម្រះអំពីភាពស្របច្បាប់នៃបណ្តឹង និង អត្ថិភាព ឬ នត្ថិភាពនៃមូលហេតុនៃការជំនុំជម្រះសាជាថ្មី</u>

ដីកាសម្រេចចាប់ផ្តើមជំនុំជម្រះសាជាថ្មី (មាត្រា315 កថាខណ្ឌទី1)

ដីកាសម្រេចលើកចោលនូវបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី(មាត្រា314 កថាខណ្ឌទី1)

ដីកាសម្រេចច្រានចោលការទាមទារឱ្យជំនុំជម្រះសាជាថ្មី(មាត្រា314 កថាខណ្ឌទី2)

ដំណាក់កាលទី២ : ការវិនិច្ឆ័យលើអង្គសេចក្តី

សាលក្រម

សាលក្រមច្រានចោលនូវការទាមទារឱ្យជំនុំជម្រះសាជាថ្មី (មាត្រា316 កថាខណ្ឌទី2)

លុបចោលនូវសាលក្រម សាលដីកាដើម ហើយសម្រេចសេចក្តីថ្មី (មាត្រា316 កថាខណ្ឌទី3)

# ការជំនុំជម្រះនៃដំណាក់កាលទី១

1 ភាពស្របច្បាប់នៃការប្តឹង

2 ការជំនុំជម្រះអំពីអត្ថិភាព ឬនត្ថិភាពនៃមូលហេតុនៃការជំនុំជម្រះសាជាថ្មី

3 ភាពបំពេញបន្ថែមនៃការជំនុំជម្រះសាជាថ្មី

4 មូលហេតុនៃការជំនុំជម្រះសាជាថ្មី

# ភាពស្របច្បាប់នៃការប្តឹង

ក្នុងករណីដែលបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីមានភាពផ្ទុយនឹងច្បាប់ តុលាការត្រូវលើកបណ្តឹងនោះចោល ដោយដីកាសម្រេច(មាត្រា 314 កថាខណ្ឌទី1)។

(ឧទាហរណ៍)

- បើសិនជាមិនបានគោរពអំឡុងពេលនៃការជំនុំជម្រះសាជាថ្មី

នេះគឺជានីតិវិធីនៃដីកាសម្រេច ដូច្នេះ មិនចាំបាច់ឆ្លងកាត់តាមការទាញហេតុផលដោយផ្ទាល់មាត់ទេ(មាត្រា310, មាត្រា114 កថាខណ្ឌទី1 វាក្យខណ្ឌទី២)។

ដូច្នេះ ចំពោះពាក្យបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីណាដែលផ្ទុយនឹងច្បាប់ តុលាការអាចចេញដីកាសម្រេចលើកចោលដោយកុំឱ្យមានការយឺតយ៉ាវបាន ដោយមិនចាំបាច់ឆ្លងកាត់តាមការទាញហេតុផលដោយផ្ទាល់មាត់។

# ដីកាសម្រេចលើកចោលពាក្យបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី

**ដីកាសម្រេច**

【សេចក្ដីសម្រេចបញ្ចប់】
“លើកចោលពាក្យបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីនៃរឿងក្ដីនេះ។”

ដើមចោទនៃការជំនុំជម្រះសាជាថ្មី អាចប្ដឹងជំទាស់បាន(មាត្រា314 កថាខណ្ឌទី4)។

# ការជំនុំជម្រះអំពីអត្ថិភាព ឬនត្ថិភាពនៃមូលហេតុនៃការជំនុំជម្រះសាជាថ្មី

ក្នុងករណីដែលបណ្តឹងនោះស្របច្បាប់ ដំណាក់កាលទី១ តុលាការត្រូវធ្វើការវិនិច្ឆ័យអំពីអត្ថិភាព ឬនត្ថិភាពនៃមូលហេតុនៃការជំនុំជម្រះសាជាថ្មី។

បើសិនជាពិនិត្យទៅមិនឃើញមានមូលហេតុនៃការជំនុំជម្រះសាជាថ្មីទេ តុលាការត្រូវចេញដីកាសម្រេចច្រានចោលនូវការទាមទារឱ្យជំនុំជម្រះសាជាថ្មី(មាត្រា314 កថាខណ្ឌទី2)។

នេះគឺជានីតិវិធីនៃដីកាសម្រេច ដូច្នេះ មិនចាំបាច់ឆ្លងកាត់តាមការទាញហេតុផលដោយផ្ទាល់មាត់ទេ(មាត្រា310, មាត្រា114 កថាខណ្ឌទី1 វាក្យខណ្ឌទី២)។ ដូច្នេះ តុលាការអាចចេញដីកាសម្រេចច្រានចោលនូវការទាមទារ ដោយកុំឱ្យមានការយឺតយ៉ាវបាន ដោយមិនចាំបាច់ឆ្លងកាត់តាមការទាញហេតុផលដោយផ្ទាល់មាត់។

# ដីកាសម្រេចច្រានចោលនូវការទាមទារឱ្យជំនុំជម្រះសាជាថ្មី

**ដីកាសម្រេច**

【សេចក្ដីសម្រេចបញ្ចប់】
“ច្រានចោលនូវការទាមទារឱ្យជំនុំជម្រះសាជាថ្មីនៃរឿងក្ដីនេះ។”

ដើមចោទនៃការជំនុំជម្រះសាជាថ្មី អាចប្ដឹងជំទាស់បាន(មាត្រា314 កថាខណ្ឌទី4)។

ប្រសិនបើដីកាសម្រេចច្រានចោលនូវការទាមទារឱ្យជំនុំជម្រះសាជាថ្មីចូលជាស្ថាពរហើយ ដើមចោទនៃការជំនុំជម្រះសាជាថ្មីមិនអាចដាក់ពាក្យបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីទៀត ដោយយកមូលហេតុដូចគ្នាបានឡើយ ។(មាត្រា314 កថាខណ្ឌទី3)។

# ការជំនុំជម្រះអំពីអត្ថិភាព ឬនត្ថិភាពនៃមូលហេតុនៃការជំនុំជម្រះសាជាថ្មី

ក្នុងករណីដែលមានមូលហេតុនៃការជំនុំជម្រះសាជាថ្មី តុលាការត្រូវចេញដីកាសម្រេចចាប់ផ្ដើមជំនុំជម្រះសាជាថ្មី។ (មាត្រា315 កថាខណ្ឌទី1)។

ក្នុងករណីនេះ តុលាការត្រូវសួរចុងចម្លើយនៃការជំនុំជម្រះសាជាថ្មី(មាត្រា315 កថាខណ្ឌទី2 )។ នេះមិនមែនជានីតិវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់ទេ ដូច្នេះ អាចធ្វើតាមរយៈលិខិតជាលាយលក្ខណ៍អក្សរបាន។

# ដីកាសម្រេចផ្ដើមជំនុំជម្រះសាជាថ្មី

## ដីកាសម្រេច

【សេចក្ដីសម្រេចបញ្ជាប់】
"ចាប់ផ្ដើមការជំនុំជម្រះស្ដីពីរឿងក្ដី (លេខនៃរឿងក្ដី) នៃសាលាដំបូងភ្នំពេញ រវាងដើមចោទនៃការជំនុំជម្រះសាជាថ្មី និង ចុងចម្លើយនៃការជំនុំជម្រះសាជាថ្មី។"

ចុងចម្លើយនៃការជំនុំជម្រះសាជាថ្មី អាចប្ដឹងជំទាស់បាន (មាត្រា315 កថាខណ្ឌទី3)។

នៅពេលដែលដីកាសម្រេចដើម្បីចាប់ផ្ដើមជំនុំជម្រះសាជាថ្មីចូលជាស្ថាពរហើយ (មាត្រា303 កថាខណ្ឌទី1), ត្រូវឈានទៅដំណាក់កាលជំនុំជម្រះអំពីអង្គសេចក្ដី។

# ភាពបំពេញបន្ថែមនៃការជំនុំជម្រះសាជាថ្មី

ទោះជាមានមូលហេតុនៃការជំនុំជម្រះសាជាថ្មីក៏ដោយ ក្នុងករណីខាងក្រោមនេះ មិនអាចទាមទារឱ្យធ្វើការជំនុំជម្រះសាជាថ្មីបានទេ (មាត្រា307 កថាខណ្ឌទី1 វាក្យខណ្ឌទី2)។

(1)ករណីដែលភាគីបានធ្វើការអះអាងអំពីមូលហេតុនោះនៅពេលធ្វើបណ្ដឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់

ឬក៏

(2)ករណីដែលភាគីបានដឹងអំពីមូលហេតុនេះហើយ តែមិនធ្វើការអះអាង

ស្ដីពីអង្គហេតុដែលត្រូវជាមូលហេតុនៃការជំនុំជម្រះសាជាថ្មី ជាបឋម ត្រូវអះអាងនៅក្នុងបណ្ដឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ តាមរយៈការដាក់ពាក្យបណ្ដឹងឧបាស្រ័យធម្មតា។ ហេតុនេះហើយ មានតែករណីដែលមិនអាចអះអាងបាននៅក្នុងបណ្ដឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់បុណ្ណោះទេ ដែលអាចអះអាងបានតាមបណ្ដឹងទាមទារសុំឱ្យជំនុំជម្រះសាជាថ្មី។

# សេចក្តីពន្យល់ត្រួសៗអំពីមូលហេតុនៃការជំនុំជម្រះសាជាថ្មី

(1) ករណីដែលមានការធ្វើផ្ទុយនឹងនីតិវិធីធ្ងន់ធ្ងរ
មាត្រា307 កថាខណ្ឌទី1 ចំណុច ក. , ខ. , គ.

(2) ករណីដែលបទល្មើសរបស់អ្នកដទៃមានឥទ្ធិពលទៅលើសាលក្រម ឬ សាលដីកាដែលបានចូលជាស្ថាពរ
មាត្រា307 កថាខណ្ឌទី1 ចំណុច ឃ. , ង. , ច. , ឆ.

(3) ករណីដែលសាលក្រម ឬ សាលដីកាជាអាទ៍ ដែលជាមូលដ្ឋាននៃសាលក្រម ឬ សាលដីកាដែលបានចូលជាស្ថាពរ ត្រូវបានផ្លាស់ប្តូរ
មាត្រា307 កថាខណ្ឌទី1 ចំណុច ជ.

(4) ករណីដែលមានការភ្លេចបញ្ចូលសេចក្តីវិនិច្ឆ័យលើចំណុចសំខាន់ៗ ដែលអាចមានឥទ្ធិពលទៅលើសាលក្រម ឬ សាលដីកាដែលបានចូលជាស្ថាពរ
មាត្រា307 កថាខណ្ឌទី1 ចំណាច ឈ.

(5) ករណីដែលសាលក្រម ឬ សាលដីកា ដែលជាកម្មវត្ថុនៃបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី មានការប៉ះពាល់ដល់សាលក្រម ឬ សាលដីកាមុនដែលបានចូលជាស្ថាពរហើយ
មាត្រា307 កថាខណ្ឌទី1 ចំណុច ញ.

# មូលហេតុនៃការជំនុំជម្រះសាជាថ្មី(1)

(1) ករណីដែលមានការផ្ទុយនឹងនីតិវិធីធ្ងន់ធ្ងរ

សាលក្រម ឬសាលដីកាអាចចងភាគីបាន ទាល់តែមានការធានានូវនីតិវិធីត្រឹមត្រូវ។
ប៉ុន្តែ បើសិនជាមានការធ្វើផ្ទុយនឹងនីតិវិធីធ្ងន់ធ្ងរ គឺមិនមានការធានាអំពីនីតិវិធីទេ។ ដូច្នេះ ល័ក្ខខ័ណ្ឌដែលជាអានុភាពចងនៃសាលក្រម ឬសាលដីកានោះ ពុំមានទេ។

ហេតុនេះហើយ ការធ្វើផ្ទុយនឹងនីតិវិធី គឺជាមូលហេតុនៃការជំនុំជម្រះសាជាថ្មី ទោះជាការធ្វើផ្ទុយនឹងនីតិវិធីនោះមានឥទ្ធិពលទៅលើខ្លឹមសារនៃសាលក្រម ឬសាលដីកានោះ ឬគ្មានក៏ដោយ។

# មូលហេតុនៃការជំនុំជម្រះសាជាថ្មី(1)-1

ពុំបានចាត់តាំងតុលាការដែលបានចេញសាលក្រម ឬ សាលដីកា ទៅតាមច្បាប់កំណត់(មាត្រា307 កថាខណ្ឌទី1 ចំណុច ក.)

(ឧទាហរណ៍)

- ការសម្រេចសេចក្តីត្រូវធ្វើដោយក្រុមប្រឹក្សាជំនុំជម្រះ៣រូប តែបែរទៅជាធ្វើការសម្រេចសេចក្តីដោយ២រូបទៅវិញ (សូមមើលមាត្រា23 កថាខណ្ឌទី3)
- ការធ្វើសាលក្រម ឬ សាលដីកាដោយអ្នកដែលមិនមានលក្ខណៈសម្បត្តិជាចៅក្រម
- ការធ្វើសាលក្រម ឬ សាលដីកាដោយចៅក្រមផ្សេងពីចៅក្រមដែលបានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ (សូមមើលមាត្រា185 កថាខណ្ឌទី1)

# មូលហេតុនៃការជំនុំជម្រះសាជាថ្មី(1)-2

ចៅក្រមដែលពុំអាចចូលរួមក្នុងការចេញសាលក្រម ឬ សាលដីកាតាមច្បាប់ បានចូលរួមក្នុងការចេញសាលក្រម ឬ សាលដីកានោះ (មាត្រា307 កថាខណ្ឌទី1 ចំណុច ខ.)

(ឧទាហរណ៍)

- មានមូលហេតុដកហូតចៅក្រមចេញ (មាត្រា27) តែចៅក្រមនោះបានចូលរួមក្នុងការជំនុំជម្រះនិងចេញសាលក្រម ឬ សាលដីកា។
  - សហព័ទ្ធរបស់ចៅក្រម ជាភាគី (មាត្រា27 កថាខណ្ឌទី1 ចំណុច ក.)
  - ចៅក្រមដែលទទួលបន្ទុករឿងក្តី ធ្លាប់មានវិវាទនៅតុលាការជាមួយនឹងដើមចោទ(មាត្រា27 កថាខណ្ឌទី1 ចំណុច ឃ.)

# មូលហេតុនៃការជំនុំជម្រះសាជាថ្មី(1)-3

មានការខ្វះសិទ្ធិតំណាងដែលច្បាប់បានកំណត់ ឬ អ្នកតំណាងដែលច្បាប់បានកំណត់ ខ្វះការប្រគល់សិទ្ធិចាំបាច់សម្រាប់ធ្វើសកម្មភាពបណ្ដឹង ឬ ខ្វះសិទ្ធិតំណាងដោយអាណត្តិ (មាត្រា307 កថាខណ្ឌទី1 ចំណុច គ.)

(ឧទាហរណ៍)

- មិនមែនជាអ្នកអាណាព្យាបាលទេ តែបានធ្វើសកម្មភាពបណ្ដឹងក្នុងនាមជាអ្នកអាណាព្យាបាល។
- មេធាវីដែលគ្មានការអាណត្តិ បានធ្វើសកម្មភាពបណ្ដឹង។
- អ្នកដែលពុំមានសិទ្ធិតំណាង បានធ្វើសកម្មភាពបណ្ដឹងក្នុងនាមជាអ្នកតំណាងរបស់នីតិបុគ្គល។

មូលហេតុនៃការជំនុំជម្រះសាជាថ្មីទាំងនេះ គឺត្រូវជាករណីលើកលែងនៃការកម្រិតអំឡុងពេល(មាត្រា311 កថាខណ្ឌទី1 វាក្យខណ្ឌទី2, កថាខណ្ឌទី3 វាក្យខណ្ឌទី2)។

# មូលហេតុនៃការជំនុំជម្រះសាជាថ្មី(2)

(2) ករណីដែលបទល្មើសរបស់អ្នកដទៃមានឥទ្ធិពលទៅលើសាលក្រម ឬ សាលដីកាដែលបានចូលជាស្ថាពរ

ត្រូវតែឱ្យមានភាពច្បាស់លាស់ថា តើជា “បទល្មើស” ឬជា“ការក្លែងបន្លំ” ឬជា “ការកែបន្លំ” ឬជា “ការថ្លែងសេចក្ដីមិនពិត”។ បើមិនដូច្នេះទេ ការជំនុំជម្រះនោះនឹងមានភាពស្មុគស្មាញ ដោយសារតែមិនដឹងថា មូលហេតុនោះគឺជាអ្វី ។

ដើម្បីឱ្យក្លាយទៅជាមូលហេតុនៃការជំនុំជម្រះសាជាថ្មី ចាំបាច់ត្រូវតែជាសាលក្រម ឬសាលដីកាចូលជាស្ថាពរ ជាអាទ៍(មាត្រា 307 កថាខណ្ឌទី2 ចំណុច ក. , ចំណុច ខ.)។

# មូលហេតុនៃការជំនុំជម្រះសាជាថ្មី(2)-1

ចៅក្រមដែលបានចូលរួមក្នុងការចេញសាលក្រម ឬ សាលដីកា បានប្រព្រឹត្តអំពើល្មើសដែលពាក់ព័ន្ធនឹងមុខងាររបស់ខ្លួនចំពោះរឿងក្តី (មាត្រា307 កថាខណ្ឌទី1 ចំណុច ឃ.)

(ឧទាហរណ៍)

- ចៅក្រមទទួលសំណូកពី X ហើយចេញសាលក្រម ឬសាលដីកាឱ្យ X ឈ្នះ។

មិនគិតថា តើអំពើឧក្រិដ្ឋនោះមានឥទ្ធិពលទៅលើលទ្ធផលនៃសាលក្រម ឬសាលដីកា ឬគ្មានឥទ្ធិពលទេ។

# មូលហេតុនៃការជំនុំជម្រះសាជាថ្មី(2)-2

បានសារភាព ឬ ត្រូវបានរារាំងក្នុងការដាក់មធ្យោបាយតទល់ ឬ ការពារខ្លួនដែលមានឥទ្ធិពលដល់សាលក្រម ឬ សាលដីកា ដោយសារបទល្មើសរបស់អ្នកដទៃ (មាត្រា307 កថាខណ្ឌទី1 ចំណុច ង.)

(ឧទាហរណ៍)

- ដោយសារតែត្រូវដើមចោទគម្រាមកំហែង ទើបសារភាព។
- ដោយសារតែបានទទួលអំពើហិង្សាពីតតិយជន ទើបមិនបានអះអាងអំពីការសង។ ឬក៏មិនបានដាក់ភស្តុតាងសំខាន់ៗ។

ចាំបាច់ត្រូវមានឥទ្ធិពលទៅលើសាលក្រម ឬសាលដីកា។

# មូលហេតុនៃការជំនុំជម្រះសាជាថ្មី(2)-3

ឯកសារ ឬ វត្ថុឯទៀតដែលបានក្លាយជាភស្តុតាងសម្រាប់សាលក្រម ឬ សាលដីកាត្រូវបានក្លែង ឬ កែប្រែដោយបន្លំ។(មាត្រា 307 កថាខណ្ឌទី1 ចំណុច ច.)

(ឧទាហរណ៍)

- មានការទទួលស្គាល់ថា កិច្ចសន្យាត្រូវបានបង្កើតឡើងដោយលិខិតនៃកិច្ចសន្យាក្លែងក្លាយ។

ចាំបាច់ត្រូវតែមានការយកភស្តុតាងនោះមកធ្វើការទទួលស្គាល់អង្គហេតុនៅក្នុងសាលក្រម ឬសាលដីកាដែលបានចូលជាស្ថាពរ។

# មូលហេតុនៃការជំនុំជម្រះសាជាថ្មី(2)-4

សេចក្តីថ្លែងការណ៍មិនពិតរបស់សាក្សី ឬអ្នកធ្វើកោសលវិច័យ ឬអ្នកបកប្រែ ឬភាគីដែលបានធ្វើសម្បថ ឬអ្នកតំណាងដែលច្បាប់បានកំណត់ដែលបានធ្វើសម្បថ បានក្លាយជាភស្តុតាងសម្រាប់សាលក្រម ឬ សាលដីកា (មាត្រា307 កថាខណ្ឌទី1 ចំណុច ឆ.)

(ឧទាហរណ៍)

- សាក្សីបានផ្តល់សក្ខីកម្មក្លែងក្លាយ។
- ដើមចោទ (ចុងចម្លើយនៃការជំនុំជម្រះសាជាថ្មី) បានផ្តល់សក្ខីកម្មក្លែងក្លាយ។

ចាំបាច់ត្រូវមានការទទួលស្គាល់នូវអង្គហេតុដោយផ្អែកលើចម្លើយជាកសិណសាក្សីនោះ នៅក្នុងសាលក្រម ឬសាលដីកាដែលបានចូលជាស្ថាពរ។

# មូលហេតុនៃការជំនុំជម្រះសាជាថ្មី(3)

(3) ករណីដែលមានការប្តូរសាលក្រម ជាអាទិ៍ ដែលត្រូវបានយកមកធ្វើជាមូលដ្ឋាននៃសាលក្រម ឬសាលដីកាដែលបានចូលជាស្ថាពរ

អាចមានករណីដែលសាលក្រម ឬសាលដីកាដែលបានចូលជាស្ថាពរ ត្រូវបានសម្រេចដោយយកសាលក្រម ឬសាលដីកា ឬការចាត់ចែងរដ្ឋបាលពិសេសណាមួយមកធ្វើជាមូលដ្ឋាន។

ក្នុងករណីបែបនេះ បើសិនជាសាលក្រម ឬសាលដីកា ឬការចាត់ចែងរដ្ឋបាលដែលត្រូវបានយកមកធ្វើជាមូលដ្ឋាននោះ ត្រូវបានផ្លាស់ប្តូរ នេះក៏ជាមូលហេតុនៃការជំនុំជម្រះសាជាថ្មីដែរ ដោយសារតែគេគិតថា គប្បីដោះស្រាយវិវាទដែលពាក់ព័ន្ធឱ្យមានឯកភាព។

# មូលហេតុនៃការជំនុំជម្រះសាជាថ្មី(3)-1

សាលក្រម ឬ សាលដីកា ឬ សេចក្ដីសម្រេចឯទៀត ផ្នែករដ្ឋប្បវេណី ឬ ផ្នែកព្រហ្មទណ្ឌ ឬ ការចាត់ចែងផ្នែករដ្ឋបាល ដែលជាមូលដ្ឋាននៃសាលក្រម ឬ សាលដីកាត្រូវបានផ្លាស់ប្ដូរ ដោយសារសេចក្ដីសម្រេច ឬ ការចាត់ចែងផ្នែករដ្ឋបាលនៅពេលក្រោយ (មាត្រា307 កថាខណ្ឌទី1 ចំណុច ជ.)

(ឧទាហរណ៍)

Pបានលក់ដីL ដែលជាកម្មសិទ្ធិរបស់ខ្លួនទៅឱ្យD។ ថ្លៃលក់គឺ ១ម៉ឺនដុល្លារអាមេរិកបូកនឹង ១០០ដុល្លារអាមេរិក ដែលជាពន្ធលើអចលនទ្រព្យក្នុងឆ្នាំនោះ។
D បានបង់ប្រាក់១ម៉ឺនដុល្លាររួចហើយ តែគាត់មិនបានបង់ប្រាក់១០០ដុល្លារទេ ព្រោះគាត់និយាយថា ១០០ដុល្លារអាមេរិកដែលជាប្រាក់ពន្ធលើអចលនទ្រព្យនោះមានបញ្ហា។ P បានប្ដឹង D ហើយតុលាការបានទទួលស្គាល់នូវប្រាក់១០០ដុល្លារនេះ ហើយសាលក្រមបានចូលជាស្ថាពរ។ តែបន្ទាប់ពីនោះ ការយកពន្ធលើអចលនទ្រព្យនោះត្រូវបានលប់ចោល។ Dអាចដាក់ពាក្យបណ្ដឹងទាមទារឱ្យធ្វើការជំនុំជម្រះសាជាថ្មីបាន ដោយហេតុថាមានការប្ដូរនូវការចាត់ចែងផ្នែករដ្ឋបាលដែលជាមូលដ្ឋាននៃសាលក្រមឬសាលដីកានោះ។

# មូលហេតុនៃការជំនុំជម្រះសាជាថ្មី(4)

(4) ករណីដែលមានការខកខានវិនិច្ឆ័យនៅក្នុងសាលក្រម ឬ សាលដីកាដែលបានចូលជាស្ថាពរ

ស្តីពីមធ្យោបាយតទល់និងការពារខ្លួនដែលភាគីបានអះអាងចំពោះចំណុចណាមួយដែលមានឥទ្ធិពលទៅលើលទ្ធផលនៃសាលក្រម ឬសាលដីកា តុលាការត្រូវតែធ្វើការវិនិច្ឆ័យ។

ក្នុងករណីដែលតុលាការមិនបានវិនិច្ឆ័យចំពោះមធ្យោបាយតទល់នឹងការពារខ្លួនដែលមានឥទ្ធិពលទៅលើលទ្ធផល វាអាចធ្វើឱ្យមានការប្រែប្រួលនូវខ្លឹមសារនៃសាលក្រម ឬសាលដីកា។

ហេតុនេះហើយ នេះក៏ជាមូលហេតុនៃការជំនុំជម្រះសាជាថ្មីដែរ។

# មូលហេតុនៃការជំនុំជម្រះសាជាថ្មី(4)-1

មានការភ្លេចបញ្ចូលសេចក្តីវិនិច្ឆ័យលើចំណុចសំខាន់ៗ ដែលអាចមានឥទ្ធិពលទៅលើសាលក្រម ឬ សាលដីកា(មាត្រា307 កថាខណ្ឌទី1 ចំណុច ឈ.)

(ឧទាហរណ៍)

Y បានអះអាងថា គាត់បានសង១ម៉ឺនដុល្លារអាមេរិករួចហើយ (ការតវ៉ាអំពីការសង)។ ក៏ប៉ុន្តែនៅក្នុងសាលក្រម ឬសាលដីកា តុលាការពុំបានធ្វើការវិនិច្ឆ័យចំពោះការតវ៉ាអំពីការសងនេះទាល់តែសោះ។

# ការភ្លេចបញ្ចូលនូវការវិនិច្ឆ័យ និង ការខកខានវិនិច្ឆ័យ【យោង】

មានពាក្យ "ខកខានវិនិច្ឆ័យ"(មាត្រា183) ដែលប្រហាក់ប្រហែលនឹង "ការភ្លេចបញ្ចូលនូវការវិនិច្ឆ័យ"(មាត្រា307 កថាខណ្ឌទី1 ចំណុច ឈ.)ដែរ។

ការខកខានវិនិច្ឆ័យ តើជាអ្វីដែរ?

ក្នុងករណីដែលមិនបានវិនិច្ឆ័យចំពោះមួយភាគនៃការទាមទារ គេហៅថា ការខកខានវិនិច្ឆ័យ។

(ឧទាហរណ៍)

X បានទាមទារឱ្យសងប្រាក់កម្ចី ដែលគាត់បានឱ្យខ្ចី៣ដង ក្នុងមួយដង១ម៉ឺនដុល្លារអាមេរិក សរុបទាំងអស់៣ម៉ឺនដុល្លារ។ តុលាការបានទទួលស្គាល់១ម៉ឺនដុល្លារ ច្រានចោល១ម៉ឺនដុល្លារ ហើយ១ម៉ឺនដុល្លារទៀត មិនបានវិនិច្ឆ័យសោះ។

# ការភ្លេចបញ្ចូលនូវការវិនិច្ឆ័យ និង ការខកខានវិនិច្ឆ័យ【យោង】

ផ្នែកនៃការទាមទារដែលខកខានវិនិច្ឆ័យ ត្រូវបានចាត់ការបន្តនៅតុលាការនោះតទៅទៀត(មាត្រា183)។ ម្ល៉ោះហើយ តុលាការត្រូវវិនិច្ឆ័យបន្ត ចំពោះការទាមទារដែលនៅសល់នោះ។

ការភ្លេចបញ្ចូលនូវការវិនិច្ឆ័យ ក៏ដូចជាការខកខានវិនិច្ឆ័យដែរ គឺជាកង្វះនៃការវិនិច្ឆ័យរបស់តុលាការ។

- អ្វីដែលជាកង្វះនៃការវិនិច្ឆ័យក្នុងដំណាក់កាលនៃការទាមទារ: ការខកខានវិនិច្ឆ័យ
- អ្វីដែលជាកង្វះនៃការវិនិច្ឆ័យក្នុងដំណាក់កាលនៃការអះអាង: ការភ្លេចបញ្ចូលនូវការវិនិច្ឆ័យ

# មូលហេតុនៃការជំនុំជម្រះសាជាថ្មី(5)

(5) ករណីដែលខ្លឹមសារនៃសាលក្រម ឬ សាលដីកាដែលបានចូលជាស្ថាពរ ផ្ទុយគ្នានឹងខ្លឹមសារនៃសាលក្រមឬសាលដីកាដែលបានចូលជាស្ថាពរមុន

នេះគឺជាករណីដែលអាជ្ញាអស់ជំនុំនៃសាលក្រមឬសាលដីកានៃបណ្ដឹងមុន (មាត្រា194) និងអាជ្ញាអស់ជំនុំនៃសាលក្រមឬសាលដីកានៃបណ្ដឹងក្រោយ ផ្ទុយគ្នា។

គេចាត់ទុកថា ជាមូលហេតុនៃការជំនុំជម្រះសាជាថ្មី ដើម្បីរំលាយចោលនូវស្ថានភាពគ្មានសង្គតិភាពនេះ។

# មូលហេតុនៃការជំនុំជម្រះសាជាថ្មី(5)-1

សាលក្រម ឬ សាលដីកា ដែលជាកម្មវត្ថុនៃបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី មានការប៉ះពាល់ដល់សាលក្រម ឬ សាលដីកាមុនដែលបានចូលជាស្ថាពរហើយ(មាត្រា307 កថាខណ្ឌទី1 ចំណុច ញ.)

ឧទាហរណ៍ មុនពេលដាក់ពាក្យបណ្តឹងនៃ【ករណីសិក្សា (រូម)】 Xបានដាក់ពាក្យបណ្តឹងដូចគ្នា (បណ្តឹងមុន)។
នៅក្នុងបណ្តឹងមុន តុលាការបានច្រានចោលនូវការទាមទារ ហើយសាលក្រម ឬសាលដីកានោះបានចូលជាស្ថាពរ។

# ករណីសិក្សា (សភាពការណ៍បន្ថែម)



# មូលហេតុនៃការជំនុំជម្រះសាជាថ្មី(5)-1

យោលតាមអាជ្ញាអស់ជំនុំនៃបណ្ដឹងមុន បណ្ដឹងក្រោយក៏ត្រូវច្រានចោលនូវការទាមទារដែរ។

ក៏ប៉ុន្តែ មិនដឹងជាមានហេតុអ្វីទេ ស្រាប់តែតុលាការមិនបានចាប់ភ្លឹកដល់បណ្ដឹងមុន ហើយអាចចេញសាលក្រមឬសាលដីកាទទួលស្គាល់នូវការទាមទារ ក្នុងបណ្ដឹងក្រោយ។

ក្នុងករណីបែបនេះ គេអាចដាក់ពាក្យបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី ដោយទាមទារឱ្យលុបចោលនូវបណ្ដឹងក្រោយបាន។

នេះគឺជាករណីលើកលែងនៃការកម្រិតអំឡុងពេល(មាត្រា311 កថាខណ្ឌទី1 វាក្យខណ្ឌទី2 , កថាខណ្ឌទី3 វាក្យខណ្ឌទី2)

# មូលហេតុនៃការជំនុំជម្រះសាជាថ្មី

ស្តីពីករណីដែលមាននៅក្នុងស្លាយដ៍បន្ទាប់ តើអាចដាក់ពាក្យបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីបានដែរឬទេ ?

# មូលហេតុនៃការជំនុំជម្រះសាជាថ្មី

ខ្ញុំចាញ់ក្ដី តែខ្ញុំបានពិនិត្យមើលឡើងវិញ ក៏បាន
រកឃើញភស្តុតាងថ្មី។ បើសិនជាមានភស្តុតាង
នេះទៅ ច្បាស់ជាតុលាការច្រានចោលនូវការ
ទាមទារហើយ។
ត្រូវដាក់ពាក្យបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជា
ថ្មី !




សាលក្រមទទួលស្គាល់នូវការទាមទារ → ចូលជាស្ថាពរ

# មូលហេតុនៃការជំនុំជម្រះសាជាថ្មី

ក៏ប៉ុន្តែ ការរកឃើញភស្តុតាងថ្មី មិនមែនជាមូលហេតុនៃការជំនុំជម្រះសាជាថ្មីទេ (ពុំមានចែងក្នុងមាត្រា307 កថាខណ្ឌទី1ទេ)។

ទោះជារកឃើញភស្តុតាងថ្មីក៏ដោយ ក៏មិនអាចប្តូរនូវអានុភាពនៃសាលក្រមឬសាលដីកាដែលបានចូលជាស្ថាពរបានដែរ។

បើសិនជាមានការទាមទារឱ្យជំនុំជម្រះសាជាថ្មី ដោយមូលហេតុរកឃើញភស្តុតាងថ្មី ត្រូវតែច្រានចោលកុំឱ្យមានការយឺតយ៉ាវ(មាត្រា314 កថាខណ្ឌទី2)។

# សេចក្តីពន្យល់ត្រួសៗអំពីនីតិវិធីនៃការជំនុំជម្រះសាជាថ្មី

បណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី: ដាក់ពាក្យបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី

ដំណាក់កាលទី១ : ការជំនុំជម្រះអំពីភាពស្របច្បាប់នៃបណ្តឹង និងអត្ថិភាពឬនត្ថិភាពនៃមូលហេតុនៃការជំនុំជម្រះសាជាថ្មី

ដីកាសម្រេចចាប់ផ្តើមជំនុំជម្រះសាជាថ្មី (មាត្រា315 កថាខណ្ឌទី1)

ដីកាសម្រេចលើកចោលនូវបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី(មាត្រា314 កថាខណ្ឌទី1)
ដីកាសម្រេចច្រានចោលការទាមទារឱ្យជំនុំជម្រះសាជាថ្មី(មាត្រា314 កថាខណ្ឌទី2)

ដំណាក់កាលទី២ : ការជំនុំជម្រះនៃអង្គសេចក្តី

សាលក្រម

សាលក្រមច្រានចោលនូវការទាមទារឱ្យជំនុំជម្រះសាជាថ្មី (មាត្រា316 កថាខណ្ឌទី2)
លុបចោលនូវសាលក្រម សាលដីកាដើម ហើយសម្រេចសេចក្តីថ្មី (មាត្រា316 កថាខណ្ឌទី3)

# ការជំនុំជម្រះនៃអង្គសេចក្តី

ក្នុងករណីដែលដីកាសម្រេចចាប់ផ្តើមជំនុំជម្រះសាជាថ្មីចូលជាស្ថាពរ បន្តពីនេះ តុលាការត្រូវធ្វើការវិនិច្ឆ័យ និង សម្រេចសេចក្តីលើអង្គសេចក្តី (មាត្រា316 កថាខណ្ឌទី1)។

នេះគឺជាការបន្តនូវនីតិវិធីនៃបណ្តឹងមុន។

- បើសិនជាមានការផ្លាស់ប្តូរចៅក្រម ចាំបាច់ត្រូវបន្តការទាញហេតុផល (មាត្រា310, មាត្រា185 កថាខណ្ឌទី2)

# ការជំនុំជម្រះនៃអង្គសេចក្ដី

ក្នុងការជំនុំជម្រះស្ដីពីអង្គសេចក្ដី ត្រូវប្រើនីតិវិធីទៅតាមលំដាប់ថ្នាក់នៃសាលក្រម ឬសាលដីកាដែលជាកម្មវត្ថុនៃការជំនុំជម្រះសាជាថ្មី (មាត្រា310)។

ក្នុងការជំនុំជម្រះសាជាថ្មីនៃសាលក្រមរបស់សាលាដំបូង ត្រូវប្រើនីតិវិធីរបស់សាលាដំបូង។

ការជំនុំជម្រះសាជាថ្មីស្ដីពីសាលដីកានៃការជំនុំជម្រះបណ្ដឹងឧទ្ធរណ៍ ត្រូវធ្វើតាមនីតិវិធីនៃការជំនុំជម្រះបណ្ដឹងឧទ្ធរណ៍ រីឯការជំនុំជម្រះសាជាថ្មីស្ដីពីសាលដីកានៃការជំនុំជម្រះបណ្ដឹងសាទុក្ខ ត្រូវធ្វើតាមនីតិវិធីនៃការជំនុំជម្រះបណ្ដឹងសាទុក្ខ។

# សេចក្ដីពន្យល់ត្រួសៗអំពីនីតិវិធីនៃការជំនុំជម្រះសាជាថ្មី

បណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី: ដាក់ពាក្យបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី

ដំណាក់កាលទី១ : ការជំនុំជម្រះអំពីភាពស្របច្បាប់នៃបណ្ដឹង និង អត្ថិភាពឬនិត្ថិភាពនៃមូលហេតុនៃការជំនុំជម្រះសាជាថ្មី

ដីកាសម្រេចចាប់ផ្ដើមជំនុំជម្រះសាជាថ្មី (មាត្រា315 កថាខណ្ឌទី1)

ដីកាសម្រេចលើកចោលនូវបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី(មាត្រា314 កថាខណ្ឌទី1)
ដីកាសម្រេចច្រានចោលការទាមទារឱ្យជំនុំជម្រះសាជាថ្មី(មាត្រា314 កថាខណ្ឌទី2)

ដំណាក់កាលទី២ : ការជំនុំជម្រះនៃអង្គសេចក្ដី

សាលក្រម

សាលក្រមច្រានចោលនូវការទាមទារឱ្យជំនុំជម្រះសាជាថ្មី (មាត្រា316 កថាខណ្ឌទី2)
លុបចោលនូវសាលក្រម សាលដីកាដើម ហើយសម្រេចសេចក្ដីថ្មី (មាត្រា316 កថាខណ្ឌទី3)

# សាលដីកានៃអង្គសេចក្តី

បើសិនជាលទ្ធផលនៃការជំនុំជម្រះអង្គសេចក្តី ឃើញថា  សាលក្រម ឬ សាលដីកាដែលបានចូលជាស្ថាពរត្រឹមត្រូវ  ត្រូវចេញសាលក្រម ឬ សាលដីកាច្រានចោលនូវការទាមទារ(មាត្រា316 កថាខណ្ឌទី2)។

តុលាការបានចាប់ផ្តើមការជំនុំជម្រះសាជាថ្មី តើអាចមានករណីដែលសាលក្រម ឬ សាលដីកាដែលបានចូលជាស្ថាពរត្រឹមត្រូវដែរឬទេ?

# សាលក្រម ឬ សាលដីកានៃអង្គសេចក្ដី

ដោយសារតែមានការធ្វើផ្ទុយនឹងនីតិវិធី តុលាការបានចាប់ផ្ដើមការជំនុំជម្រះសាជាថ្មី តែលទ្ធផលនៃការជំនុំជម្រះសាជាថ្មីគឺដូចគ្នា។




សាលក្រមទទួលស្គាល់នូវការទាមទារ → ចូលជាស្ថាពរ

# សាលក្រម ឬ សាលដីកានៃអង្គសេចក្តី

ក្នុងករណីនេះ ត្រូវច្រានចោលការទាមទារនូវការជំនុំជម្រះសាជាថ្មី(មាត្រា316 កថាខណ្ឌទី2)។




សាលក្រមទទួលស្គាល់នូវការទាមទារ → ចូលជាស្ថាពរ

# សាលក្រម ឬ សាលដីកានៃអង្គសេចក្ដី

ហេតុដូច្នេះ  ការជំនុំជម្រះសាជាថ្មីត្រូវបានចាប់ផ្ដើម  តែអាចមានករណីដែលលទ្ធផលនៃជំនុំជម្រះសាជាថ្មី គឺដូចគ្នានឹងលទ្ធផលនៃសាលក្រម ឬ សាលដីកាដែលបានចូលជាស្ថាពរដែរ។

- ភាគច្រើន ការជំនុំជម្រះសាជាថ្មីគឺដោយមូលហេតុផ្ទុយនឹងនីតិវិធី (មាត្រា308 កថាខណ្ឌទី1 ចំណុច ក.~គ.)។

ក្នុងករណីនេះ  តុលាការចេញសាលក្រម ឬ សាលដីកាច្រានចោលការទាមទារនូវការជំនុំជម្រះសាជាថ្មី។

- នេះមិនមែនជាការច្រានចោលនូវការទាមទារក្នុងអង្គសេចក្ដីទេ។

# សាលក្រម ឬ សាលដីកាច្រានចោលការទាមទារនូវការជំនុំជម្រះសាជាថ្មី

## សាលក្រម ឬ សាលដីកា

【សេចក្ដីសម្រេចបញ្ចប់】
“ច្រានចោលការទាមទារនូវការជំនុំជម្រះសាជាថ្មីនៃរឿងក្ដីនេះ។”

ដើមចោទនៃការជំនុំជម្រះសាជាថ្មី  អាចប្ដឹងឧបាស្រ័យបានទៅតាមថ្នាក់នៃការជំនុំជម្រះ។

ករណីនៃការជំនុំជម្រះសាជាថ្មីចំពោះសាលក្រមនៃការជំនុំជម្រះលើកទី១ : ប្ដឹងឧទ្ធរណ៍

ករណីនៃការជំនុំជម្រះសាជាថ្មីចំពោះសាលដីកានៃការជំនុំជម្រះនៃបណ្ដឹងឧទ្ធរណ៍ : ប្ដឹងសាទុក្ខ

# សាលក្រមឬសាលដីកានៃអង្គសេចក្តី

ក្រៅពីករណីខាងលើនេះ  ត្រូវលុបចោលនូវសាលក្រម ឬ សាលដីកាដែលបានចូលជាស្ថាពរ ហើយចេញសាលក្រម ឬ សាលដីកាថ្មី(មាត្រា316 កថាខណ្ឌទី3)។

# ករណីសិក្សា (រូម)

ករណីលុបចោលសាលក្រម ឬ សាលដីកាទទួលស្គាល់ការទាមទារដែលបានចូលជាស្ថាពរ ហើយច្រានចោលការទាមទារ




សាលក្រមទទួលស្គាល់នូវការទាមទារ → ចូលជាស្ថាពរ

# សាលក្រមឬសាលដីកានៃអង្គសេចក្ដី ១

## សាលក្រម

【សេចក្ដីសម្រេចបញ្ចប់】

“លុបចោលនូវសាលក្រមនៃរឿងក្ដី (លេខនៃរឿងក្ដី) នៃសាលាដំបូងភ្នំពេញ រវាងដើមចោទនៃបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី និង ចុងចម្លើយនៃបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី ។ ច្រានចោលនូវការទាមទាររបស់ចុងចម្លើយនៃការជំនុំជម្រះសាជាថ្មី។”

ចុងចម្លើយនៃការជំនុំជម្រះសាជាថ្មី អាចប្ដឹងឧបាស្រ័យបាន ទៅតាមថ្នាក់នៃការជំនុំជម្រះ។

ករណីនៃការជំនុំជម្រះសាជាថ្មីចំពោះសាលក្រមនៃការជំនុំជម្រះលើកទី១ : ប្ដឹងឧទ្ធរណ៍

ករណីនៃការជំនុំជម្រះសាជាថ្មីចំពោះសាលដីកានៃការជំនុំជម្រះនៃបណ្ដឹងឧទ្ធរណ៍ : ប្ដឹងសាទុក្ខ

# ករណីសិក្សា

ករណីលុបចោលនូវសាលក្រមច្រានចោលការទាមទារដែលបានចូលជាស្ថាពរ ហើយទទួលស្គាល់នូវការទាមទារ




សាលក្រមច្រានចោលនូវការទាមទារ → ចូលជាស្ថាពរ

# សាលក្រមឬសាលដីកា ២

## សាលក្រម

【សេចក្តីសម្រេចបញ្ចប់】
“លុបចោលនូវសាលក្រមនៃរឿងក្តី (លេខនៃរឿងក្តី)នៃសាលាដំបូងភ្នំពេញ រវាងដើមចោទនៃបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី និង ចុងចម្លើយនៃបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី ។ បង្គាប់ឱ្យចុងចម្លើយនៃការជំនុំជម្រះសាជាថ្មី បង់ប្រាក់១ម៉ឺនដុល្លារអាមេរិកទៅឱ្យដើមចោទនៃការជំនុំជម្រះសាជាថ្មី។”

ចុងចម្លើយនៃការជំនុំជម្រះសាជាថ្មី អាចប្តឹងឧបាស្រ័យបាន ទៅតាមថ្នាក់នៃការជំនុំជម្រះ។

ករណីនៃការជំនុំជម្រះសាជាថ្មីចំពោះសាលក្រមនៃការជំនុំជម្រះលើកទី១ : ប្តឹងឧទ្ធរណ៍

ករណីនៃការជំនុំជម្រះសាជាថ្មីចំពោះសាលដីកានៃការជំនុំជម្រះនៃបណ្តឹងឧទ្ធរណ៍ : ប្តឹងសាទុក្ខ

# ការផ្អាកការអនុវត្តដោយការជំនុំជម្រះសាជាថ្មី

ការពន្យល់ខាងលើនេះ គឺជានីតិវិធីនៃបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី។

បន្ទាប់មក ខ្ញុំសូមពន្យល់អំពីការផ្អាកការអនុវត្តដោយការដាក់ពាក្យបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី។

# ការផ្អាកការអនុវត្តដោយការជំនុំជម្រះសាជាថ្មី




សាលក្រមទទួលស្គាល់នូវការទាមទារ → ចូលជាស្ថាពរ

# ការផ្អាកការអនុវត្តដោយការជំនុំជម្រះសាជាថ្មី

មានរបបផ្អាកការអនុវត្តដោយការដាក់ពាក្យបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី(មាត្រា366 កថាខណ្ឌទី1ចំណុច ក.)។

នេះគឺជារបបផ្អាកការអនុវត្តមួយរយៈពេល ក្នុងករណីដែលមានការដាក់ពាក្យបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី រហូតដល់ពេលបានទទួលលទ្ធផលនៃការដាក់ពាក្យបណ្តឹងនោះ។

ពេលមានសាលក្រម ឬសាលដីកាចូលជាស្ថាពរហើយ តាមធម្មតា គេអាចអនុវត្តដោយបង្ខំហើយ។ ហេតុនេះ ការសុំផ្អាកការអនុវត្តនោះ តម្រូវឱ្យមានលក្ខខណ្ឌតឹងរ៉ឹងណាស់។

# ការផ្អាកការអនុវត្តដោយការជំនុំជម្រះសាជាថ្មី

【ល័ក្ខខ័ណ្ឌ】

(1) ស្ថានភាពដែលត្រូវបានអះអាងថាជាមូលហេតុឧបាស្រ័យនោះ ហាក់ដូចជាមានមូលហេតុផ្លូវច្បាប់

ហើយ

(2) មានសេចក្តីបញ្ជាក់ដំបូងអំពីហេតុការណ៍ពិតនោះ

ចំពោះដីកាសម្រេចអំពីការផ្អាកការអនុវត្ត ឬដីកាសម្រេចលើកចោលនូវពាក្យសុំ មិនអាចប្តឹងឧបាស្រ័យបានទេ។

- ដោយសារតែគ្មានបញ្ញត្តិណាមួយចែងថា “អាចប្តឹងជំទាស់បាន” (មាត្រា259 កថាខណ្ឌទី2)

# ការផ្អាកការអនុវត្តដោយការជំនុំជម្រះសាជាថ្មី

(1) ស្ថានភាពដែលត្រូវបានអះអាងថាជាមូលហេតុឧបាស្រ័យនោះ ហាក់ដូចជាមានមូលហេតុផ្លូវច្បាប់

ការអះអាងរបស់ដើមបណ្តឹងនៃការជំនុំជម្រះសាជាថ្មី ត្រូវតែហាក់ដូចជាមានមូលហេតុណាមួយដែលមានចែងក្នុងចំណុចណាមួយនៃមូលហេតុនៃការជំនុំជម្រះសាជាថ្មី(មាត្រា307 កថាខណ្ឌទី1)។

បើសិនជាអង្គហេតុដែលអះអាងដោយដើមបណ្តឹងនៃការជំនុំជម្រះសាជាថ្មីមិនត្រូវនឹងមូលហេតុណាមួយនៃការជំនុំជម្រះសាជាថ្មីទេ គឺមិនស្របនឹងលក្ខខណ្ឌនេះទេ។

- "រកឃើញភស្តុតាងថ្មី" : មិនមែនជាមូលហេតុនៃការជំនុំជម្រះសាជាថ្មីទេ
- "ការផ្តល់សក្ខីកម្មមិនត្រឹមត្រូវ" : បើសិនជាគ្មានសាលក្រមឬសាលដីកាដែលទទួលស្គាល់ថា សក្ខីកម្មនោះមិនត្រឹមត្រូវទេ មិនមែនជាមូលហេតុនៃការជំនុំជម្រះសាជាថ្មីទេ (មាត្រា307 កថាខណ្ឌទី2)។

# ការផ្អាកការអនុវត្តដោយការជំនុំជម្រះសាជាថ្មី

(2) មានសេចក្តីបញ្ជាក់ដំបូងអំពីហេតុការណ៍ពិតនោះ

ស្តីពីការអះអាងដែលដើមចោទនៃការជំនុំជម្រះសាជាថ្មីថា ជាមូលហេតុនៃការជំនុំជម្រះសាជាថ្មី ចាំបាច់ត្រូវធ្វើការបញ្ជាក់ដំបូង(មាត្រា131)។

ទាល់តែស្របនឹងល័ក្ខខ័ណ្ឌពីរ ទើបអាចទទួលស្គាល់នូវការផ្អាកការអនុវត្ត។

# ការផ្អាកការអនុវត្តដោយការជំនុំជម្រះសាជាថ្មី

ការជំនុំជម្រះសាជាថ្មី គេមិនងាយទទួលស្គាល់ស្រួលៗទេ។ មានតែករណីយ៉ាងពិសេសតិចតួចណាស់ ដែលតុលាការទទួលស្គាល់។ ហេតុនេះហើយ ការផ្អាកការអនុវត្តដោយសារបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីក៏អាចទទួលស្គាល់បានតែក្នុងករណីពិសេសណាស់ប៉ុណ្ណោះ។

# ការផ្អាកការអនុវត្តដោយការជំនុំជម្រះសាជាថ្មី

បានតទល់គ្នារហូតដល់តុលាការកំពូល ក៏ប៉ុន្តែចាញ់គេទៅ។ តែមិនចង់បង់ប្រាក់១ម៉ឺនដុល្លារទេ។ តើត្រូវធ្វើយ៉ាងដូចម្តេចដែរ ?




សាលក្រមទទួលស្គាល់នូវការទាមទារ → ចូលជាស្ថាពរ

# ការផ្អាកការអនុវត្តដោយការជំនុំជម្រះសាជាថ្មី

គ្មានមូលហេតុជំនុំជម្រះសាជាថ្មីទេ តែបើដាក់ពាក្យបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី ហើយដាក់ពាក្យសុំឱ្យផ្អាកការអនុវត្តក៏ល្អម្យ៉ាងដែរ។




សាលក្រមទទួលស្គាល់នូវការទាមទារ → ចូលជាស្ថាពរ

# ការផ្អាកការអនុវត្តដោយការជំនុំជម្រះសាជាថ្មី

ដូចដែលបានពន្យល់ខាងលើនេះ ដើម្បីឱ្យបានរួចផុតពីការអនុវត្តដោយបង្ខំ អាចមានករណីដែលគេដាក់ពាក្យបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីដោយគ្មានហេតុផល ហើយដាក់ពាក្យសុំផ្អាកការអនុវត្ត។

ការដាក់ពាក្យបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីបែបនេះ គឺជាការធ្វើចាកពីគោលគំនិតនៃការជំនុំជម្រះសាជាថ្មីខ្លាំងណាស់ ហើយជាការប្រើដោយបំពាន ដូច្នេះមិនអាចទទួលស្គាល់បានឡើយ។

បើសិនជាទទួលស្គាល់នូវការសុំឱ្យផ្អាកការអនុវត្តរហូតដល់ករណីប្រើរបបជំនុំជម្រះសាជាថ្មីដោយការបំពានបែបនេះទៅ វាអាចរារាំងនូវការសម្រេចសិទ្ធិ(អាចអនុវត្តដោយបង្ខំបាន)របស់ភាគីដែលបានទទួលសាលក្រម ឬសាលដីកាទទួលស្គាល់នូវការទាមទារដែលបានចូលជាស្ថាពរ។

# ការផ្អាកការអនុវត្តដោយការជំនុំជម្រះសាជាថ្មី

តុលាការដែលបានទទួលពាក្យសុំឱ្យផ្អាកការអនុវត្តបែបនេះ មិនចាំបាច់បង្គាប់ឱ្យផ្អាកការអនុវត្តទេ គឺត្រូវតែលើកចោល។

ទាល់តែប្រហែលជាមានមូលហេតុនៃការដាក់ពាក្យបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី ទើបអាចផ្អាកការអនុវត្តបាន។





# សូមអរគុណ !

**International Cooperation Department**
**Research and Training Institute**
**Ministry of Justice of Japan**

**4th Floor, Osaka Nakanoshima National Government Building,**
**1-1-60 Fukushima, Fukushima-ku, Osaka City 553-0003**
**Phone: 81-6-4796-2153 Fax: 81-4796-2157**
**E-mail: icdmoj@moj.go.jp**